# អំពីទោសប្រហារជីវិត ៖ តើកម្ពុជាគួររក្សាការលុបទោសប្រហារជីវិត ឬប្រើទោសប្រភេទនេះឡើងវិញ?

ដោយ បណ្ឌិត មាស ប៊ូរ៉ា និង លោក នូ ចន្ថា
ខែ មេសា ឆ្នាំ ២០១៩

## ១. សេចក្តីផ្តើម

សិទ្ធិរស់រានមានជីវិត គឺជាសិទ្ធិមេ (Parent Right) ក្នុងន័យថា មានជីវិតទើបមានសិទ្ធិដទៃទៀត។ មាត្រា ៦នៃ កតិកាសញ្ញា ស្តីពី សិទ្ធិនយោបាយ និង ពលរដ្ឋ ឆ្នាំ ១៩៦៦ មិនបានហាមឃាត់ទោសប្រហារជីវិតទេ។ ប្រទេសមួយចំនួន បានប្រកាសលុបនូវទោសប្រហារជីវិត សូម្បីក្នុងច្បាប់ធម្មនុញ្ញ ដែលជាច្បាប់កំពូល ខណៈដែលប្រទេសខ្លះ បានរក្សាទោសប្រភេទនេះ ទោះបីបានចូលជាភាគីនៃកតិកាសញ្ញាក្តី។

កម្ពុជា ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានលុបចោលនូវទោសប្រហារជីវិតទាំងស្រុង។ ឆ្លើយតបនឹងព្រឹត្តិការណ៍នៃបទឧក្រិដ្ឋធ្ងន់ធ្ងរ ដូចជា ការរំលោភសេពសន្ថវៈ កក្រើកក្នុងប្រព័ន្ធទំនាក់ទំនងសង្គម មានគំនិតផ្ទុយគ្នា រវាងក្រុមមនុស្សចង់រក្សាការលុបបំបាត់ និងក្រុមមនុស្ស ដែលចង់កែរដ្ឋធម្មនុញ្ញ ដើម្បីប្រើទោសប្រហារជីវិតឡើងវិញ។ ការរក្សាទុក ឬ ការប្រើទោសប្រភេទនេះឡើងវិញ ជាបញ្ហាស្មុគស្មាញ ផ្នែកសង្គមនយោបាយ និងច្បាប់។

គោលបំណងនៃអត្ថបទនេះ នឹងបង្ហាញនូវគុណសម្បត្តិនៃការរក្សាទុកការលុបបំបាត់ ឬ ដាក់ឡើងវិញ ដោយមិនបង្ហាញនូវសេចក្តីសន្និដ្ឋានជាក់លាក់ និងទុកជូនមិត្តអ្នកអាន សម្រេច។ ជាបឋម អត្ថបទនឹងបង្ហាញនូវសវតាផ្លូវច្បាប់កម្រិតអន្តរជាតិនៃការលុបបំបាត់ទោសប្រហារជីវិត មុននឹងពិភាក្សា ពាក់ព័ន្ធនឹងក្របខ័ណ្ឌច្បាប់កម្ពុជា។

## ២. ទោសប្រហារជីវិត

### ២.១. ការហាមឃាត់ទោសប្រហារជីវិតជាអន្តរជាតិ

សិទ្ធិរស់រានមានជីវិត ជាសិទ្ធិមេ (parent rights) ក្នុងន័យថាមានជីវិតទើបមានសិទ្ធិទាំងឡាយ។ វាជាសិទ្ធិធម្មជាតិ និងមានភ្ជាប់មកជាមួយ (natural and inherent right) សិទ្ធិចម្បង (fundamental right)។ វា

ទំនងជាហេតុនេះហើយ ទើបមានលិខិតូបករណ៍អន្តរជាតិ ទាំងមិនចងកាតព្វកិច្ច (soft law) ឬចងជាកាតព្វកិច្ច (treaties) ជាច្រើន ត្រូវបានអនុម័តរៀបចំឡើង ចែងលុបបំបាត់ទោសប្រហារជីវិត។[1] ក្នុងចំណោមនោះ មានឯកសារចំនួនពីរ ដែលអ្នកស្រាវជ្រាវ តែងតែនិយាយយោងដល់ នាពេលនិយាយដល់ ការលុបបំបាត់ទោសប្រហារជីវិត គឺកតិកាសញ្ញា ស្តីពី សិទ្ធិនយោបាយ និងប្រជាពលរដ្ឋ[2] ព្រមទាំងពិធីសារ បន្ថែមលើ កតិកាសញ្ញានេះ ដែលនិយាយយ៉ាងច្បាប់ដល់ការលុបបំបាត់ទោសប្រហារជីវិត។[3] មាត្រា ៦ នៃកតិកា និយាយលម្អិតអំពីទោសប្រហារជីវិត ចែងថា៖

> *១. មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិតភ្ជាប់មកជាមួយ។ សិទ្ធិនេះ ត្រូវបានការពារដោយច្បាប់។ មិនមានជនណាម្នាក់ ត្រូវបានដកហូតជីវិតដោយបំពារបំពានទេ។ ២. នៅក្នុងប្រទេស ដែលមិនបានលុបទោសប្រហារជីវិត ទោសនេះត្រូវបានប្រើសម្រាប់តែបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត អនុលោមតាមច្បាប់នៅជាធរមាន នាពេលដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត និង មិនផ្ទុយនឹងបទប្បញ្ញត្តិនៃកតិកាសញ្ញានេះ ព្រមទាំង អនុសញ្ញា ស្តីពីការបង្ការ និង ផ្តន្ទាទោសអំពើប្រល័យពូជសាសន៍។ ទោសនេះ អាចត្រូវបានអនុវត្ត អនុលោមតាមសាលក្រមស្ថាពរ ចេញដោយតុលាការមានសមត្ថកិច្ច។ ៣. នៅពេលដែលការដកហូតជីវិត បង្កើតជាអំពើប្រល័យពូជសាសន៍ មិនមានអ្វីក្នុងមាត្រានេះ អនុញ្ញាតឲ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ ផ្អាកការគោរពក្នុងទម្រង់ណាមួយ នូវកាតព្វកិច្ច ក្រោមបទប្បញ្ញត្តិ នៃ អនុសញ្ញាស្តីពីការបង្ការ និង ផ្តន្ទាទោសអំពើប្រល័យពូជសាសន៍។ ៤. បុគ្គលណាមួយ ទទួលទោសប្រហារជីវិតមានសិទ្ធិក្នុងការស្នើសុំការអនុគ្រោះ ឬបន្ធូរទោស។ ការលើកលែងទោស អនុគ្រោះទោស ឬបន្ធូរទោសប្រហារជីវិត អាចត្រូវបានផ្តល់ក្នុងគ្រប់ប្រភេទបទល្មើស។ ៥. ទោសប្រហារជីវិត នឹងមិនត្រូ*

---

[1] The *Protocol to the American Convention on Human Rights to Abolish the Death Penalty*, adopted by the General Assembly of the Organization of American States in 1990; *Protocol No. 6 to the European Convention for the Protection of Human Rights and Fundamental Freedoms ["European Convention on Human Rights"] concerning the abolition of the death penalty*, adopted by the Council of Europe in 1982; *Protocol No. 13 to the Convention for the Protection of Human Rights and Fundamental Freedoms [European Convention on Human Rights] concerning the abolition of the death penalty in all circumstances*, adopted by the Council of Europe in 2002.

[2] The International Covenant on Civil and Political Rights, United Nations, Treaty Series, vol. 999, p. 171, Entry into force: 23 March 1976, https://www.refworld.org/docid/3ae6b3aa0.html [accessed 17 April 2019] (ICCPR).

[3] Second Optional Protocol to the International Covenant on Civil and Political Rights, A/RES/44/128, Entry into force 11 July 1991, *https://www.refworld.org/docid/3ae6b3a70.html*

*វអនុវត្តចំពោះកុមារក្រោម ១៨ឆ្នាំ និងស្ត្រីមានផ្ទៃពោះ។ ៦. មិនមានអ្វីក្នុងមាត្រានេះ ត្រូវបានផ្អែកក្នុងការពន្យា ឬ រារាំងនូវការលុបបំបាត់ទោសប្រហារជីវិត ដោយរដ្ឋភាគីនៃកតិកាសញ្ញានេះឡើយ។*[4]

តាមខ្លឹមសារនេះ ទោសប្រហារជីវិត នៅតែអនុញ្ញាតឲ្យមាន ក៏ប៉ុន្តែសម្រាប់បទល្មើសធ្ងន់ធ្ងរ ដូចជាអំពើមនុស្សឃាតទុកជាមុនជាដើម។ ការសម្រេចប្រហារជីវិត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបង្កើតឡើងដោយច្បាប់។ សេចក្តីសម្រេច ត្រូវតែស្ថាពរ ឆ្លងកាត់នូវនីតិវិធី ត្រឹមត្រូវ (due process) ដែលសិទ្ធិ និងសេរីភាពជនល្មើសត្រូវបានធានា។ សេចក្តីសម្រេចធ្វើឡើងដោយតុលាការ បង្កើតដោយច្បាប់ជាមុន។ ក្នុងន័យនេះ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានសំដែងការបារម្ភចំពោះតុលាការយោធា កាត់សេចក្តីដាក់ទោសប្រហារជីវិត ជនស៊ីវិលដែលប្រព្រឹត្តបទល្មើស។[5]

មាត្រា ៦ បានចែងហាមមិនឲ្យដាក់ទោសប្រហារជីវិត ទៅលើក្រុមមនុស្ស ជាការសម្លាប់រង្គាល ឬការសម្លាប់មនុស្ស ទោះបីតាមយន្តការច្បាប់ព្រហ្មទណ្ឌ ជាមួយចេតនាបំបាត់ពូជសាសន៍ ដែលអាចនឹងក្លាយជាបទប្រល័យពូជសាសន៍ ចែងក្នុងអនុសញ្ញា ឆ្នាំ ១៩៤៨ ស្តីពីការបង្ការ និង ផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ទេ។[6] ក្នុងករណីចុងក្រោយនេះ រដ្ឋជាភាគី មានកាតព្វកិច្ចធ្វើការកាត់ទោស អ្នកប្រព្រឹត្តិការសម្លាប់ ហើយអ្នកប្រព្រឹត្ត អាចនឹងទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល (Individual Criminal Liability) [7]ក្រោមច្បាប់

---

[4] *Article 6.* 1. Every human being has the inherent right to life. This right shall be protected by law. No one shall be arbitrarily deprived of his life. 2. In countries which have not abolished the death penalty, sentence of death may be imposed only for the most serious crimes in accordance with the law in force at the time of the commission of the crime and not contrary to the provisions of the present Covenant and to the Convention on the Prevention and Punishment of the Crime of Genocide. 1 This penalty can only be carried out pursuant to a final judgement rendered by a competent court. 3. When deprivation of life constitutes the crime of genocide, it is understood that nothing in this article shall authorize any State Party to the present Covenant to derogate in any way from any obligation assumed under the provisions of the Convention on the Prevention and Punishment of the Crime of Genocide. 4. Anyone sentenced to death shall have the right to seek pardon or commutation of the sentence. Amnesty, pardon or commutation of the sentence of death may be granted in all cases.5. Sentence of death shall not be imposed for crimes committed by persons below eighteen years of age and shall not be carried out on pregnant women. 6. Nothing in this article shall be invoked to delay or to prevent the abolition of capital punishment by any State Party to the present Covenant, ICCPR, *supra* note 2.

[5] UN Human Rights Committee, General Comment No. 36 (2018) on article 6 of the International Covenant on Civil and Political Rights, on the right to life, CCPR/C/GC/36, 30 October 2018, para. 45.

[6] The Convention on the Prevention and Punishment of the Crime of Genocide, United Nations, Treaty Series, vol. 78, p. 277, 12 January 1951, articles 1, 5 and 6, see https://www.refworld.org/docid/3ae6b3ac0.html [accessed 17 April 2019].

[7] Genocide Convention, *supra* note 6, Article 4.

ជាតិ ឬយន្តការយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court)[8]។ ជាមួយគ្នានេះដែរ មាត្រា ៦ ហាមមិនឲ្យប្រើទោសប្រហារជីវិតក្នុងលក្ខណៈរើសអើង (discrimination)។

មាត្រា ៦ ចែងមិនឲ្យប្រើទោសប្រហារជីវិត ចំពោះកុមារអាយុក្រោម ១៨ឆ្នាំឬនារីមានផ្ទៃពោះ។ ក្រៅពីមូលហេតុមនុស្សធម៌ វាមិនជាការទទួលយកបានទេ ចំពោះការប្រហារជីវិត កុមារដែលគេជឿថា មានកម្រិតពិចារណា វែកញែកថាអំពីណាមួយខុស ឬត្រូវ ដោយសារភាពក្មេងខ្ចីគំនិតរបស់ពួកគេ។[9] ជាចុងក្រោយ មាត្រាដដែល បង្គាប់ឲ្យមានយន្តការ ដែលជនល្មើសអាចបន្តប្តឹងផ្តល់ទៅតុលាការជាន់ខ្ពស់ ដើម្បីបន្ថយទោសប្រហារជីវិត មកជាទោសមួយជីវិត។[10]

សន្ធិសញ្ញា ឬអត្ថបទគម្រូ ដែលមិនពាក់ព័ន្ធផ្ទាល់ដល់ ទោសប្រហារជីវិត ក៏មានចែងអំពីការហាមឃាត់ទោសប្រហារជីវិតដែរ។ ជាក់ស្តែង សន្ធិសញ្ញាគម្រូ ស្តីពីបត្យាប័ន បានចែងតម្រូវឲ្យរដ្ឋធ្វើបត្យាប័ន (extradition) មនុស្ស ទាមទារឲ្យរដ្ឋសុំបញ្ជូន មិនឲ្យប្រើទោសប្រហារជីវិត នៅពេលរដ្ឋបានបញ្ជូនទៅដល់ ។[11] មានកិច្ចព្រមព្រៀងទ្វេភាគីមួយចំនួន បានចែងស្រដៀងគ្នានេះផងដែរ។[12]

បន្ថែមពីលើខ្លឹមសារក្នុងច្បាប់ យុត្តិសាស្ត្រ ឬសេចក្តីសម្រេចចិត្តរបស់ស្ថាប័នអន្តរជាតិពាក់ព័ន្ធ បានជួយបំភ្លឺខ្លឹមសារ ឬពង្រីកន័យបន្ថែមពាក់ព័ន្ធការលុបបំបាត់ទោសប្រហារជីវិត។ គណៈកម្មាធិការ បានអះអាងថា ទោះបីទោសប្រហារជីវិតមិនត្រូវបានហាមឃាត់ ក៏ប៉ុន្តែ វិធីសាស្ត្រប្រហារជីវិត ឬ ការឃុំខ្លួនជនល្មើសមុនពេលប្រហារជីវិត អាចជាទង្វើអមនុស្សធម៌ (ill-treatment) ផ្ទុយនឹងមាត្រា ៧ នៃកតិកាសញ្ញាដដែល

---

[8] Rome Statute of the International Criminal Court, available at https://www. refworld.org /docid/3ae 6b3a84 .html [accessed 17 April 2019], article 25.

[9] Juveniles and the Death Penalty, https://www.aclu.org/other/juveniles-and-death-penalty

[10] ICCPR, *supra* note 2, article 6.

[11] UN Model Treaty on Extradition, A/RES/45/116, *https://www.un.org/documents/ga/res/45/a45r116.htm*

[12] ប្រសិនបើបទល្មើស ដែលបត្យាប័នត្រូវបានស្នើឡើង មានទោសប្រហារជីវិត ក្នុងប្រទេសស្នើសុំ បត្យាប័ននឹងអនុញ្ញាតទាល់តែ រដ្ឋត្រូវបានស្នើសុំជឿថា ប្រទេសស្នើសុំ បង្ហាញនូវការធានាគ្រប់គ្រាន់ថា បុគ្គលនឹងត្រូវបញ្ជូន នឹងមិនទទួលទោសប្រហារជីវិតទេ, Article 5 (e) of Treaty between the Kingdom of Cambodia and the Russian Federation on Extradition, 1 February 2017, *https://www.mfaic.gov.kh/wp-content/.../Treaty-of-Extradition-Cambodia-Russia.pdf*

ដែលចែងហាមឃាត់អំពើទារុណកម្ម និងមិនគម្បី៖ *"គណៈកម្មាធិការ...យល់ឃើញថាអង្គហេតុរកឃើញដោយគណៈកម្មាធិការ បង្ហាញពីការរំលោភមាត្រា ៧ នៃកតិកាសញ្ញា"* ។[13]

យុត្តិសាស្ត្រ *Soering* របស់តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប ជាយុត្តិសាស្ត្រនាំមុខ (Landmark Jurisprudence) ពាក់ព័ន្ធការប្រហារជីវិត និង ការបំពានសិទ្ធិរបស់ជនល្មើស។ *Soering* មានសញ្ជាតិអាឡឺម៉ង់ ប្រព្រឹត្តបទល្មើសមនុស្សឃាត នៅក្នុងប្រទេសអាមេរិកប្រឈមមុខនឹងទោសប្រហារជីវិត។ គាត់បានរត់គេចទៅនៅក្នុងប្រទេសអង់គ្លេស។ សហរដ្ឋអាមេរិកបានស្នើសុំឲ្យប្រទេសអង់គ្លេសបញ្ជូន *Soering* មកកាន់សហរដ្ឋអាមេរិកវិញ។ គាត់អះអាងថា បរិយាកាសរង់ចាំការប្រហារជីវិត (death row phenomenon) នៅក្នុងសហរដ្ឋអាមេរិក បំពានសិទ្ធិរួចផុតពីអំពើទារុណកម្ម និង ការប្រព្រឹត្ត មិនគប្បីរបស់គាត់។ ដូចនេះ ប្រទេសអង់គ្លេសមិនត្រូវបញ្ជូនគាត់ទេ ពីព្រោះអាចផ្ទុយនឹងមាត្រា ៣ ដែលចែងអំពីការហាមឃាត់ទារុណកម្ម ឬអំពើមិនគប្បី។ តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប បានសម្រេចដូចការអះអាងរបស់គាត់មែន៖ *"ក្នុងករណីដែលសេចក្តីសម្រេចរបស់ រដ្ឋលេខាធិការ ក្នុងការធ្វើបត្យាប័នអ្នកប្តឹងទៅសហរដ្ឋអាមេរិក ត្រូវបានអនុវត្ត វានឹងមានការរំលោភមាត្រា ៣ "*។[14] មានការអះអាងផងដែរ ថាការដាក់ទោសប្រហារ ជីវិតជាកាតព្វកិច្ច ឬដាច់ខាត (mandatory death penalty) សម្រាប់បទល្មើស មួយចំនួន ដោយប្រទេសមួយ ចំនួន ខុសនឹងមាត្រា ៦។[15]

---

[13] មិនមានបុគ្គលណាម្នាក់ ត្រូវទទួលរងអំពើទារុណកម្ម ឬ ទណ្ឌកម្ម ឬការប្រព្រឹត្ត អមនុស្សធម៌ បន្ទាបបន្ថោក ឬឃោរឃៅ។ ជាពិសេស មិនមានជនណាមួយទទួលរងនូវការពិសោធន៍ វិទ្យាសាស្ត្រ ឬវេជ្ជសាស្ត្រ ដោយគ្មានការព្រមព្រៀងដោយសេរី, ICCPR, *supra* note 2, Article 7។ UN Human Rights Committee, *Chitat Ng v. Canada*, Communication No. 469/1991, Doc.CCPR/C/49/D/469/1991 (1994), 7 January 1994, para.17.

[14] *Soering v United Kingdom* 161 (1989) Eur Court HR (ser A) *("Soering").* Stephan Breitenmoser, *Human Rights v. Extradition: The Soering Case*, 11(3) Michigan Journal of International Law, 1999.

[15] គណៈកម្មាធិការពិចារណាថា ប្រព័ន្ធដាក់ទោសប្រហារជីវិតជាកាតព្វកិច្ចដូចនេះ (mandatory capital punishment) នឹងដកហូតសិទ្ធិចម្បងរបស់អ្នកប្តឹង សិទ្ធិរស់រានមានជីវិត ដោយគ្មានការពិចារណាថាតើ ទម្រង់ទណ្ឌកម្មពិសេសនេះ មានលក្ខណៈសមស្របក្នុងស្ថានភាពនៃសំណុំរឿងរបស់គាត់។ អត្ថិភាពនៃសិទ្ធិក្នុងការស្នើសុំអនុគ្រោះទោស ឬបន្ធូរទោស ដូចចែងតម្រូវក្នុងមាត្រា ៦ កថាខ័ណ្ឌ៤ នៃកតិកាសញ្ញា នឹងមិនធានានូវការការពារគ្រប់គ្រាន់ដល់សិទ្ធិរស់រានមានជីវិត ...។ គណៈកម្មាធិការរកឃើញថា ការអនុវត្តទោសប្រហារជីវិត ក្នុងសំណុំរឿងអ្នកប្តឹងនេះ បង្កើតជាការដកហូតជីវិតដោយបំពារបំពាន ផ្ទុយនឹងមាត្រា ៦ នៃកតិកាសញ្ញា, see UN Human Rights Committee, *Thompson v. St. Vincent and the Grenadines*, Communication No. 806/1998, 18 October 2000, para. 8.2.

## ២.២. ការហាមឃាត់ទោសប្រហារជីវិតកម្រិតជាតិ

ក្នុងកម្រិតជាតិ ច្បាប់ជាតិ ឬសូម្បីច្បាប់ធម្មនុញ្ញក៏បានចែងហាមឃាត់ទោសប្រហារជីវិតទាំងស្រុង សម្រាប់គ្រប់ប្រភេទនៃបទល្មើស។[16] ប្រទេសខ្លះ រក្សាទុកសម្រាប់បទល្មើសឃោឃៅ ដូចជាប្រេស៊ីល អ៊ីស្រាអ៊ែលជាដើម។[17] អ្វីជានិន្នាការគឺថា មានរដ្ឋមួយចំនួនតូច ប្រហែល ៥៦ ប៉ុណ្ណោះរក្សាទោសប្រហារជីវិត ដូចជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី ថៃ សហរដ្ឋអាមេរិក និងវៀត ណាម ជាដើម។[18] ភាគច្រើននៃរដ្ឋទាំងនោះសម្រេច មិនប្រើទោសនេះ ដោយប្រើទោសផ្សេងដូចជា ដាក់ពន្ធនាគារមួយជីវិតជំនួសវិញ។[19] ប្រទេសពាក់កណ្ដាលនៃតំបន់អាស៊ាន បានលុបបំបាត់ទោសប្រភេទនេះ រាប់បញ្ចូលប្រទេសកម្ពុជាផងដែរ។[20] ច្បាប់ប្រទេសមួយចំនួន ចែងមិនឲ្យប្រហារជីវិតលើមនុស្សជរា ឬ ស្ត្រីដែលទើបនឹងសម្រាលកូន។[21]

ការអនុវត្តរបស់តុលាការរបស់ប្រទេសមួយចំនួន បង្ហាញពីភាពវិជ្ជមានហួសពីការរំពឹងទុក។ ជាក់ស្តែងក្នុងសំណុំរឿង *Burns* ផ្ទុយពីទម្លាប់របស់រដ្ឋាភិបាលកាណាដា ដែលសុំឲ្យរដ្ឋទាមទារការបញ្ជូន មិនឲ្យប្រើទោសប្រហារជីវិត ក្នុងករណីបទល្មើសធ្ងន់ធ្ងរ តុលាការកំពូលកាណាដា បានតម្រូវឲ្យរដ្ឋាភិបាល សុំការធានាគ្រប់ប្រភេទបទល្មើសដែលមានទោសប្រហារជីវិត មិនឲ្យរដ្ឋសុំបញ្ជូនប្រើទោសប្រហារជីវិត លើកលែងក្នុងករណីពិសេស ដើម្បីឲ្យស្របនឹងធម្មនុញ្ញស្តីពីសិទ្ធិរបស់កាណាដា (Canadian Charter of Rights) ដែលបានលុបទោសប្រហារជីវិត។[22] នេះជាការវិវត្តដ៏វិជ្ជមានទទួលបានការសាទរពីសកម្មជនសិទ្ធិមនុស្ស។

---

[16] ១០៣ ប្រទេសបានលុបបំបាត់ទោសប្រហារជីវិត។ Amnesty International, Abolitionist and Retentionist Countries as of July 2018, p.1, *https://www.amnesty.org/en/documents/act50/6665/2017/en/*

[17] Amnesty International, Abolitionist and Retentionist Countries as of July 2018, *id.*, p.1.

[18] Amnesty International, Abolitionist and Retentionist Countries as of July 2018, *supra* note 16, p.2.

[19] 2017 Research shows a global trend towards abolition of the death penalty, but more work remains, https://www.amnestyusa.org/reports/research-shows-a-global-trend-towards-abolition-of-the-death-penalty-but-more-work-remains/

[20] កម្ពុជា ឡាវ ហ្វីលីពីន ប្រ៊ុយណេ និងភូមា។ Amnesty International, Abolitionist and Retentionist Countries as of July 2018, *supra* note 16, p.2.

[21] ក្រមព្រហ្មទណ្ឌវៀតណាម ឆ្នាំ ២០១៥, No. 100/20159/QH13, មាត្រា ៣៦ (៤)។ *https://www.wipo.int/edocs/lexdocs/laws/en/vn/vn086en.pdf*

[22] UN Human Rights Committee, *Roger Judge v. Canada*, CCPR/C/78/D/829/1998, 13 August 2003, para. 8.21 cited *United States v. Burns* (Neutral citation 2001 SCC 7. [2001] S.C.J No. 8).

ក្រោយពិនិត្យឯកសារអន្តរជាតិ និងជាតិ ព្រមទាំងយុត្តិសាស្ត្រអន្តរជាតិ និងជាតិ យើងអាចសន្និដ្ឋានបានថា មាននិន្នាការលុបបំបាត់ ឬផ្អាកនូវការប្រើប្រាស់ទោសប្រហារជីវិត ដោយសារភាពសំខាន់នៃសិទ្ធិ និងផលវិបាកក្នុងករណី ទោសប្រហារជីវិតត្រូវបានប្រើ។ មនុស្សម្នាក់ដែលត្រូវបានសម្លាប់ហើយមិនអាចរស់ឡើងវិញបានទេ (irreparable consequence)។[23] វាក៏អាចមានករណីសម្លាប់មនុស្សស្លូតត្រង់ដែលមិនបានប្រព្រឹត្ត ហើយ ជាលទ្ធផលរដ្ឋបានចេញលុយសង ដល់ជនរងគ្រោះនៃអំពើការកាត់សេចក្តីខុសឆ្គង (wrongful conviction)។[24] រដ្ឋខ្លះ អាចប្រើទោសប្រហារជីវិត ទៅលើមេដឹកនាំក្រុមប្រឆាំង ដើម្បីបំបិទការតវ៉ា។[25] វាក៏មានករណីរាយការណ៍ផងដែរថា ទោសប្រហារជីវិតត្រូវបានប្រើលើជនល្មើសស្បែកខ្មៅ ជាងជនល្មើសស្បែកស (discrimination)។[26]

## ២.៣. ការរក្សាការលុបទោសប្រហារជីវិត ឬដាក់ប្រើឡើងវិញ (ករណីកម្ពុជា)

មាត្រា ៣២ នៃច្បាប់ធម្មនុញ្ញឆ្នាំ ១៩៩៣ បានសម្រេចលុបទោសប្រហារជីវិត៖ *ទោសប្រហារជីវិតមិនត្រូវមានឡើយ។* នេះមិនមែនជារឿងចៃដន្យទេ។ អ្វីជាមូលហេតុចម្បង គឺកម្ពុជាធ្លាប់រងនូវ ការសម្លាប់រង្គាលក្នុងអំឡុងរបបកម្ពុជាប្រជាធិតេយ្យ ចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩។[27] វាក៏ជាមូលហេតុចម្បងមួយដែរ ដោយសារកម្ពុជាជាភាគីនៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ មុនពេលដែលរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រូវបានអនុម័ត។ ទោះបីជាយ៉ាងនេះក្តីកម្ពុជាមិនទាន់ជាភាគីនៃពិធីសារទី២ ស្តីពីការលុបបំបាត់ទោសប្រហារជីវិត បន្ថែមលើកតិកាសញ្ញាស្តីពីសិទ្ធិនយោបាយ និងប្រជាពលរដ្ឋទេ។[28]

---

[23] Execution is the ultimate, irrevocable punishment, https://www.amnesty.org/en/what-we-do/death-penalty/

[24] Since 1973, for example, more than 160 prisoners sent to death row in the USA have later been exonerated or released from death row on grounds of innocence, https://www.amnesty.org/en/what-we-do/death-penalty/.

[25] Opposition leader and more than a hundred supporters face the death penalty in Cameroon, see https://www.amnestyusa.org/reports/cameroon-opposition-leader-and-more-than-a-hundred-supporters-face-the-death-penalty/

[26] Davide C. Baldus et al., *Racial Discrimination and the Death Penalty in the Post Furman Era: An Empirical and Legal Overview, with Recent Finding from Philadelphia*, 83 Cornell Law Review, 1998, p.1738,

[27] ECCC, D6.1.197, Dr. Ewa Tabeau and They Kheam, Khmer Rouge Victims in Cambodia, April 1975 – January 1979. A Critical Assessment of Major Estimates, 2009, p. 18 (English), *available* at www.eccc.gov.kh.

[28] Treaty ratification and reporting (Cambodia), see http://cambodia.ohchr.org/en/rule-of-law/overview

ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសថាសេចក្តីព្រាងច្បាប់ដំបូង ស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលយោងដល់ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដាក់ទោសប្រហារជីវិត ខុសនឹងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣៖

> *យល់ឃើញថា មាត្រា ៣ វាក្យខ័ណ្ឌទី១ នៃច្បាប់នេះ បានយោងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និងចង្អុលមាត្រា នៃក្រមព្រហ្មទណ្ឌនេះចំនួន ១០ ដែលក្នុងចំណោមនោះ មាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ បានចែងថា៖ "ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី"។ មាត្រា ២១ នៃក្រមព្រហ្មទណ្ឌ ដែលបានបញ្ជាក់ថា "ទោសឧក្រិដ្ឋកម្មគឺជាទោសសំលាប់"។ ដូច្នេះ ទាំងអក្សរ ទាំងខ្លឹមសារវាក្យខ័ណ្ឌពាក់ព័ន្ធនេះ មានន័យផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលមាត្រា ៣២ វាក្យខ័ណ្ឌទី២ បានចែងថា៖ "ទោសប្រហារជីវិតមិនត្រូវអោយមានឡើយ"*។[29]

ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មានចែងដាក់ទោសបទប្រល័យពូជសាសន៍ (genocide) ប្រឆាំងមនុស្សជាតិ (crime against humanity) និងឧក្រិដ្ឋកម្មសង្គ្រាម (war crime) ជាបទល្មើសក្រោមច្បាប់អន្តរជាតិ (crime under international law) គ្មានអាជ្ញាយុកាលចោទប្រកាន់ (statute of limitation) មានទោសត្រឹមតែទោសជាប់ពន្ធនាគារមួយជីវិត។[30]

ការធ្វើវិសោធនកម្ម ប្រើទោសប្រហារជីវិត អាចប៉ះពាល់សិទ្ធិសេរីភាពបុគ្គល និងអាចផ្ទុយនឹងកាតព្វកិច្ច ចែងក្នុងកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលនឹងនាំឲ្យមានការរិះគន់ពីមជ្ឈដ្ឋានទូទៅ។

ការសម្រេចសេចក្តីថាជនល្មើសពិតជាបាន ប្រព្រឹត្តល្មើសសមនឹងទទួលទោសប្រហារជីវិត ផ្អែកទៅលើភស្តុតាង ការបង្ហាញហួសពីវិមតិសង្ស័យ (beyond reasonable doubt) ដោយព្រះរាជអាជ្ញា។ នេះទាមទារនូវពេលវេលា ធនធាន សមត្ថភាពមន្ត្រីពាក់ព័ន្ធ និងយន្តការការងារមានប្រសិទ្ធភាព ដើម្បីធានានីតិវិធីប្រកបដោយយុត្តិធម៌ មិនកាត់ទោសប្រហារជីវិតមនុស្សខុស។ យើងទទួលស្គាល់ថា យន្តការ និងដំណើរការនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានប្រសើរច្រើន ក៏ប៉ុន្តែនៅមានការងារជាច្រើនត្រូវធ្វើ ដើម្បីធានា ការប្រើប្រាស់ទោសប្រហារជីវិតត្រឹមត្រូវ ប្រសិនបើ ទោសប្រភេទនេះ ត្រូវបានប្រកាន់យកឡើងវិញ។

---

[29] Decision of the Constitutional Council of Cambodia, No. 040/002/2001, KBDH.C of 12 February 2001.

[30] មាត្រា ១៨៣, ១៨៣ និង ១៨៤, ១៨៨ និង ១៩៣ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

សាធារណជន តាមរយៈប្រព័ន្ធបណ្តាញសង្គម ឃើញនូវអំពើសាហាវយង់ឃ្នង អសីលធម៌ ដូចជាឪពុកបង្កើតរំលោភកូនបង្កើតរបស់ខ្លួន នាំឲ្យពួកគេខឹងក្រោធជាខ្លាំង។ ពួកគេ អាចស្នើ ឬគាំទ្រឲ្យប្រើទោសប្រហារជីវិត ឡើងវិញ ជាមួយការជឿថា ការធ្វើដូចនេះ នឹងនាំឲ្យថយនូវករណីរំលោភកុមារដោយឪពុកបង្កើត។ របៀបធ្វើការងារប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ទាមទារឲ្យមានការធ្វើអង្កេតលក្ខណៈវិទ្យាសាស្ត្រមួយ ថាតើការប្រើទោសប្រហារជីវិតឡើងវិញ គួរប្រកាន់យក និងថាតើវាពិតជានាំឲ្យមានការបង្ការ ឬបន្ថយបទល្មើសដែរឬទេ?។ ទិន្នន័យនេះ ពិតជាសំខាន់ក្នុងក្របខ័ណ្ឌនៃគោលនយោបាយព្រហ្មទណ្ឌ និងការងារប្រកបដោយវិជ្ជាជីវៈ ដើម្បីអ្នកធ្វើគោលនយោបាយ ដាក់ផែនការត្រឹមត្រូវ។

លទ្ធផលនៃការអង្កេត អាចបង្ហាញថា ការដាក់ទោសប្រហារជីវិត បែរជាមិនជួយនាំឲ្យមានការថយចុះនៃបទល្មើសធ្ងន់ធ្ងរ[31] បែរជាបង្កផលលំបាកជាបន្ថែម ជាពិសេសក្នុងករណីដែល ឪពុកជាអ្នករំលោភ ជាមេគ្រួសារ ត្រូវបានប្រហារជីវិត ធ្វើឲ្យគ្រួសារតែលតោល ជនរងគ្រោះជាកូនគ្មានអ្នកទំនុកបំរុង ក្លាយជាជនរងគ្រោះបន្ថែម (double victim)។ អ្វីដែលធ្ងន់ធ្ងរជាងនេះ ប្រសិនបើមានករណីកាត់ទោសច្រឡំ។ បន្ថែមពីនេះ ក្នុងបរិបទសង្គម កូនកម្រនឹងចង់ឲ្យគេសម្លាប់ឪពុកណាស់ ទោះបី ឪពុកជាមនុស្សអាក្រក់យ៉ាងណាក្តី។

គេអាចអះអាងថា ទោសធ្ងន់បំផុត គឺការដាក់ទោសមួយជីវិត ក៏មានប្រសិទ្ធភាពបង្ក្រាបបទល្មើសផងដែរ ប្រសិនបើការអនុវត្តច្បាប់មានប្រសិទ្ធភាព យុត្តិធម៌ និងស្មើភាព។ ការប្រើទោសប្រហារជីវិត តែមិននាំឲ្យបន្ថយចំនួនការប្រព្រឹត្តបទល្មើស បង្ហាញពីការដាក់ថ្នាំ មិនត្រូវរោគ ដោយសារគេមិនបានគិតពីដើមចមដ៏ត្រឹមត្រូវនាំឲ្យមានការរំលោភសន្លវៈ ដូចជា គ្រឿងស្រវឹង ឬការប្រើគ្រឿងញៀន ការអាចមើលបានដោយសេរី តាមប្រព័ន្ធបណ្តាញសង្គម កន្លែងកាហ្វេវីដេអូមួយចំនួន នូវរឿងអាសអាភាស នាំឲ្យអ្នកទស្សនាមានតណ្ហា ប្រព្រឹត្តអំពើរំលោភសន្លវៈ មិនរើសមុខថាជនរងគ្រោះជាកូនរបស់ខ្លួន។

---

[31] មិនមានភស្តុតាងគួរឲ្យជឿបានថា ទោសប្រហារជីវិតរារាំងបទឧក្រិដ្ឋមានប្រសិទ្ធភាព ជាងការដាក់ទោសពន្ធនាគារមួយជីវិតទេ។ រដ្ឋដែលមានច្បាប់ដាក់ទោសប្រហារជីវិត មិនមានអត្រាបទឧក្រិដ្ឋ ឬបទមនុស្សឃាតទាប ជាងរដ្ឋដែលមិនមានច្បាប់ប្រភេទនេះទេ, *See* The Death Penalty: Questions and Answers, *https://www.aclu.org/other/death-penalty-questions-and-answers*

ប្រសិនបើដូចនេះមាន ថ្នាំដែលសក្តិសិទ្ធិ គឺ ការអនុវត្តច្បាប់ដ៏តឹងរឹង ប្រកបដោយយុត្តិធម៌ រួមផ្សំនឹងការកម្រិតមើលគេហទំព័រ ឬបណ្តាញសង្គម មួយចំនួនដែលបង្ហាញរូបភាពអាសអាភាព និងវិធានការបណ្តុះបណ្តាលបន្ថែមដល់សាធារណជនអំពីច្បាប់ និងផលវិបាកនៃបទល្មើស។ វាជាវិធានការរួមផ្សំ ពហុវិស័យ (multiple and integrated measure) ប្រកាន់យកបន្តិចម្តងៗ គ្មានដំណើរថយក្រោយ (regression) ដែលចុងបញ្ចប់ យើងនឹងគ្រប់គ្រងបញ្ហាបាន។

*ដូចនេះ តើត្រូវរក្សាការលុបទោសប្រហារជីវិត ឬធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញ ដាក់ឲ្យប្រើទោសប្រហារជីវិតឡើងវិញ?*